-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៨/៣៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

**សំរេច**

ប្រការ ១ : ប្រគល់ជាបណ្តោះអាសន្នជូនក្រុមប្រឹក្សាធម្មនុញ្ញនូវអគារស ( ក្នុងវិមានរដ្ឋចំការមន ) សំរាប់ធ្វើជាទីស្នាក់ការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ រហូតដល់រាជរដ្ឋាភិបាលដោះស្រាយបានទីតាំងថ្មីជូន ក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ២ : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដោះស្រាយថវិកាជូនក្រុមប្រឹក្សាធម្មនុញ្ញសំរាប់ដំណើរការរួមទាំងប្រាក់បៀវត្ស និងថវិកាសំរាប់ ប្រើប្រាស់ក្នុងការទិញមធ្យោបាយ សំភារៈ និងឧបករណ៍ប្រើប្រាស់ សំរាប់រៀបចំអោយទីស្នាក់ការ និងដំណើរការជាប្រចាំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៨

**សេចក្តីសំរេចលេខ ២៣ សសរ**

**ស្តីពីការបើកថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាតាមរូបភាព បង់ថ្លៃ នៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ស្តីពីការបង្កើតក្រសួងអប់រំ និងយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-តាមសំណើរបស់ ក្រសួងអប់រំ និង យុវជន និងកីឡា

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចបើកថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច សិក្សាតាមរូបភាពបង់ថ្លៃ ចាប់ពីឆ្នាំ ១៩៩៨-៩៩ នេះតទៅ ។

**ប្រការ ២ :** លក្ខខ័ណ្ឌចូលសិក្សា :

ជនគ្រប់រូបដែលមាន :

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ( Bac II ) ឬ សញ្ញាបត្រដែលមានតំលៃស្មើមួយតាមការវាយតំលៃរបស់គណៈកម្មាធិការក្រសួងអប់រំ យុវជន និងកីឡា ។

-បានទទួលជោគជ័យក្នុងការប្រលងតេស្ត ។

**ប្រការ ៣ :** ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច មានរយៈពេលសិក្សាបួនឆ្នាំ ។ ចំពោះអ្នកដែលមានប្រកាសនីយបត្រជាន់ខ្ពស់នីតិសាស្ត្រ ឬវិទ្យាសាស្ត្រសេដ្ឋកិច្ច អាចចូលរៀននៅឆ្នាំទី៣បាន ។ នៅចុងឆ្នាំទី៤ និស្សិតត្រូវសរសេរសារណា និងការពារគំរោងរបស់ខ្លួន ដើម្បីទទួលយកបរិញ្ញាបត្រ។ បរិញ្ញាបត្រនេះ មានតំលៃស្មើនឹងបរិញ្ញាបត្រនីតិសាមញ្ញ តែសន្លឹកសញ្ញាបត្រមានពត៌មានខុសគ្នា ចេញអោយដោយមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និងទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

ប្រព័ន្ធសិក្សាបង់ថ្លៃ និងប្រព័ន្ធសិក្សានីតិសាមញ្ញ មិនអាចឆ្លងគ្នា ទៅវិញទៅមកបានទេ ។

ចុងឆមាសនៃ ឆ្នាំសិក្សានីមួយៗ និស្សិតត្រូវប្រលងបញ្ចប់គ្រប់មុខវិជ្ជាដែលមាន ក្នុងកម្មវិធីប្រកបដោយជោគជ័យ ។

ក្នុងករណីលទ្ធផលមិនបានតាមការកំណត់ ឬអវត្តមាន ៣/៥ នៃម៉ោងសិក្សា តាមមុខវិជ្ជាត្រូវត្រួតថ្នាក់ ។ ករណីល្មើសធ្ងន់ធ្ងរនៃបទបញ្ជារបស់មហាវិទ្យាល័យ ត្រូវលុបឈ្មោះ ចេញ ពីបញ្ជីសិក្សា ។

ប្រការ ៤ : ព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ត្រូវបង្កើតក្រុមប្រឹក្សាភិបាលមួយ ដើម្បីទទួលខុសត្រូវលើផ្នែកសិក្សា រដ្ឋបាលនិងហិរញ្ញកិច្ច និងត្រូវធ្វើបទបញ្ជាផ្សេងៗ ដើម្បីគ្រប់គ្រងថ្នាក់នេះអោយមានគុណភាពល្អ ។

ប្រការ ៥ : តំលៃនៃការសិក្សា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃមហាវិទ្យាល័យ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ នឹងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

★ ★ ★

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ២៤ សសរ

### ស្តីពីការប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ទៅជា វិទ្យាស្ថានជាតិគ្រប់គ្រង និង ការបើកថ្នាក់ បរិញ្ញាបត្រ សិក្សាតាមរូបភាពបង់ថ្លៃ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ និងយុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស